655

# អារម្ភកថា

ពុទ្ធសាសនបណ្ឌិត្យ បានបោះពុម្ពផ្សាយអត្ថបទ "ពាក្យកាព្យនិរាសនគរវត្ត" នេះ រួចម្ដងមកហើយ គឺផ្សាយក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ឆ្នាំ ១៩៣៤ លេខ ៧-៨-៩ ។ កាលគ្រានោះ អ្នកនិពន្ធនៃពាក្យកាព្យ បានយកសំណៅមកប្រគល់ឲ្យពុទ្ធសាសនបណ្ឌិត្យ ចុះផ្សាយ ដោយលោកជាអ្នកពេញចិត្តក្រៃលែងចំពោះអក្សរសាស្ត្រ ។ យើងក៏សូមថ្លែងអំណរដ៏លើសលុបចំពោះកវីរូបនេះផង ។

ពពួកអ្នកសិក្សាស្រាវជ្រាវ និងអ្នកនិយមពាក្យកាព្យឃ្លោងដែលធ្លាប់អាន ធ្លាប់សិក្សាអត្ថបទនេះ ជាច្រើននាក់ បានមកសុំឲ្យយើងចាត់ចែងយកមកបោះពុម្ពសាឡើងជាថ្មីម្ដងទៀត ធ្វើជាសៀវភៅមួយដោយឡែក ។ យើងក៏ចាត់លោក **លី.ធាមតេង** អ្នកស្រាវជ្រាវប្រចាំវិជ្ជាឋានយើង ឲ្យរើអត្ថបទនេះមកផ្ទៀងផ្ទាត់សេចក្ដី និងតម្រូវអក្ខរាវិរុទ្ធដែលភាំងភាត់ កាលបោះពុម្ពលើកមុន ឲ្យបានត្រឹមត្រូវ ហើយនិងធ្វើឧបលក្ខណៈខ្លះពន្យល់ពាក្យណាដែលពិបាក ៗ ដូចជាពាក្យដែលគេធ្លាប់ប្រើតែកាលពីសម័យនោះ, ពាក្យខ្លះក្លាយមកពីភាសាបរទេស និងពាក្យខ្លះទៀតជាសំដីអ្នកស្រុកនៅភូមិភាគបាត់ដំបង - សៀមរាប - ហើយដែលអ្នកខេត្តដទៃទៀត

ពុំសូវផ្តាច់ៗ ។ ការបន្ថែមនយលក្ខណៈបែបនេះ ដើម្បីជួយសម្រួលអ្នកអានទូទៅ ជាពិសេសអ្នកសិក្សាដែលមានវ័យនៅក្មេងៗ ឲ្យបានងាយយល់ អាចឈោងចាប់ន័យនិងរសខ្លឹមសារ ក្នុងពាក្យកាព្យនេះ បានច្បាស់លាស់ ។ ប៉ុន្តែទោះបីជាទំយ៉ាងនេះក្តី ក៏គង់នៅមានខ្វះចន្លោះច្រើនទៀតមិនខាន យើងក៏សុំអភ័យទោសចំពោះលោកអ្នកអាន អំពីការខ្វះខាតភ្លាំង-ភ្លាត់ខ្វះក្រៅចេតនានេះ ផងដែរ ។

គោលបំណងធំរបស់យើង គឺការបំផុសនូវពាក្យកាព្យ និង ធ្វើឲ្យលេចភ្លឺត្រចះត្រចង់ឡើងនូវសម្ផស្សកាព្យ សំនួនវោហារ ព្រមទាំងអត្ថ-រសជាខ្លឹមសារ ដែលកវីបានបង្កប់នៅលាយឡំក្នុងអត្ថបទនេះ, ព្រោះថារបស់ល្អយ៉ាងណាក៏ដោយ បើគេពុំបានលាតត្រដាងឲ្យឃើញរូបឆោមទេ ស្ថិតនៅលាក់ខ្លួនដោយគៀនគោះ, របស់នោះឯងក៏ពុំមានប្រយោជន៍អ្វីឡើយ ហើយជាការឥតអំពើថែមទៀត ។ ដូច្នេះ យើងត្រូវតែព្យាយាមលើកយកមកផ្សាយជាសាធារណៈ ទើបបានជាការសិក្សា យកជាបទពិចារណា បង្កើនស្មារតីចេះដឹង ឲ្យកាន់តែបរិបូណ៌ឡើង ដើម្បីជាហិត-ប្រយោជន៍ចំពោះអ្នកអាន អ្នកសិក្សាទូទៅ ។

ពិតមែនហើយ អត្ថបទនេះ អ្នកនិពន្ធអធិប្បាយតាមការពិតទាំងស្រុង គឺលោកឃើញយ៉ាងណា ឮយ៉ាងណា គិតយល់យ៉ាងណា លោក



ក៏សរសេរយ៉ាងនោះ, ប៉ុន្តែធម្មតាការពិតពេក រមែងប៉ះពាល់ទៅលើនេះលើនោះ នាំឲ្យកើតរង្កៀសខ្លះ ក៏មិនខានដែរ ។ តែណ្ហើយចុះ យើងសុំចម្លងទាំងស្រុងតាមអត្ថបទដើម ឥតហ៊ានកែ ហ៊ានបំផ្លើស មួយម៉ាត់ណាឡើយ ត្បិតចង់រក្សាលក្ខណៈដើមឲ្យនៅបរិសុទ្ធ, ហេតុការណ៍ចាស់ៗ ក៏ឲ្យនៅគ្រប់ សម្រាប់ឲ្យអ្នកអាន អ្នកសិក្សាធ្លុះមើលឃើញរបៀបរបបការរស់នៅនៃស្រុកយើង និងចិត្តគំនិតរបស់អ្នកស្រុកយើងកាលពីសម័យនោះ ។ ដូច្នេះ បើលោកអ្នកអានឆ្ងល់ត្រង់ណា, ឃើញពុំសមត្រង់ណា ក៏សុំរិះគិត យកកាលទេសៈធ្វើជាប្រមាណ ទើបកាត់សេចក្តីសង្ស័យទាំងនោះបាន ។

ទីបំផុត ពុទ្ធសាសនបណ្ឌិត្យ សូមថ្លែងសេចក្តីកោតសរសើរយ៉ាងជ្រាលជ្រៅ ចំពោះសន្តានចិត្តលោកកវី សុត្តន្តប្រីជា **ឥន្ទ** ដែលបានទុកស្នាដៃជាច្រើនក្នុងអក្សរសាស្ត្រ និងវប្បធម៌ជាតិ រាប់ថាជាអ្នកប្រាជ្ញអក្សរ-សាស្ត្រមួយរូបយ៉ាងឆ្នើម ក្នុងដើមសតវត្សទី ២០ ។

ភ្នំពេញ ថ្ងៃទី ៣០ មីនា ១៩៦៧

ពុទ្ធសាសនបណ្ឌិត្យ

# និរាសនគរវត្ត

(១)

១ និរាសរតនវត្តនគរសែនវិចិត្ត

កាលចេញចាកលាកបរសេមរមិត្រ

កែវដីរ៉ាគូជិវិតកិសម័យ ។

ដោយមានការបក្រពាក្យវង្សក្រស័ត្រ

ស៊ីសុវត្ថិព្រះកែវហ្វាសុទ្ឡាវៃ

ព្រះចៅក្រុងកម្ពុជាធិបតៃ

មានព្រះទ័យហ្វាយប៉ីងពោធិញាណ ។

ទ្រង់យាងមកនគរវត្តសមោសរ

ចាត់បដិសន្ធរណ៍ទីបុរាណ

បរិច្ចាគរាជទ្រព្យប្រដាប់ទាន

បំពេញញាណសម្ពោធិបញ្ញា ។

កំណត់ថ្ងៃយាងនោះចុះខាងខ្នើត

ប្រាំបួនកើតកទ្របទមាសា

ថ្ងៃព្រហស្បតិ៍លេខប្រាំឆ្នាំរកា

ពេលសុរិយាត្រៃសែងព្រះរង្សី ។

លោកចៅហ្វាយខែត្រស្រុកព្រះដំបង
ជានាយកងចាត់ការរាជការថ្មី
ព្រមទាំងលោកកុម្មិសែរអធិបតី
ចិត្តភក្តីត្រេកត្រន់ទាំងទេហារ ៗ
រៀបចាត់ចែងតែងតួតាមទំនួល
ទៅទទួលព្រះបរមចៅចក្រា
លោកក៏យកខ្ញុំបាទទៅផងណា
ព្រោះមេត្តាចង់ឲ្យយល់ទីបុរាណ ៗ
គ្រាន់នឹងទ័តទទឹងប្រសាសន៍លោក
ក្រែងជួនស្មោកកើតទោសមោះដល់ប្រាណ
ខំតែកាត់ចិត្តលះលាកល្យាណ
គួបុរាណកាលកម្មចាំចាកចរ ៗ

ដល់ពេលផ្ទុំលោកធំចុះចាកស្ថាន
ឡើងរថយានទឹមសេះដំបូរ
សារថីជំនាញទាញបើកបរ
បត់បរចុះដល់កំពង់ទឹក ៗ



ពួកពលការបារាំងទាំងខ្មែរយួន
សឹងក្តែងខ្លួនជូនដំណើរអឹកធឹក
ពួកទាហានជើងខ្មៅប្រចាំសឹក
ដង្ហែត្រឹកចុះកប៉ាល់ជាស្រង៉ា ៗ
នាយតៃកុងទាញខ្សែសំម្រេកង់
លាន់បីដងម័តឡូស្រាយយុថ្កា
សទិមពេញកំបេញបមឧត្តរ
តាមគង្គាហូរត្រង់ដម្រង់ចរ ៗ
តៃកុងយួនបេះក្បួនបង្កូតត្រង់
កាត់ដម្រង់តាមជ្រោយប្រាំងសាគរ
ចក្រកិវិលក់យកពន្ធិកខួរ
អ្នកទករត់មើលគ្រប់លំនៅ ៗ

កប៉ាល់លឿនដល់គយខ្ញុំគយគន់
យល់ដំបន់មេគយប្រចាំផ្លូវ
មានសសរគោមតាំងមុខលំនៅ
មើលៗទៅទីលំនៅមិនសមសក្តិ ៗ
ផ្ទះរយាកតាករយាលស្បូវរយោង

ភាពជាខ្មែរកែជាភេទយ៉ាងជាថ្នាក់
ឱគយនេះយ៉ាងជាគ្នាខាតប្រាក់
គ្រាន់តែត្រួតមើលអ្នកចូលចេញក្រៅ ៗ
នឹងមានហូតពន្ធដារការក៏ទេ
គ្រាន់តែគេចូលប្រាប់ក៏ហួសទៅ
ឱគយនេះអត់ពន់ធន់តាំងនៅ
ធ្វើតែស្រូវដាំច្បារចំការស៊ី ៗ
រាជការសៀមតាំងគយនៅចុងស្រុក
ពុំឃើញមានទំនុកឲ្យហូតអ្វី
គោតមេគយនៅចាំជាប្រក្រតី
រាជការថ្មីលោកលើកពុំបំរុង ៗ

ឱអ្នកគយគេធ្វើចំការស្រែ
មិនដូញប្រែយ៉ាងយើងអ្នកស្រុកក្នុង
គោតគេរកធនធានគ្មានគោងកុង
ស៊ូកក់ផុងជិតកាយកំភពជា ៗ
ស្ដាយតែរូបនារីពងស្រឡៅ
ចុះស្ងួនស្រូវត្រូវកំដៅព្រះសុរិយា



ជិតតាំងដីកក់ផងហ្មងកក្ដា
អនិច្ចាជាតិអ្នកក្រត្រដទៅ ៗ
ប្រសិនមានមាសប្រាក់និងសក្តិយស
ស៊ីក៏ខ្ពស់ដេកក៏ខ្ពស់ឥតមោះមៅ
បំរុងលាបទឹកអប់និងប្រេងម្សៅ
កាល់ចាប់ខ្មៅតែងខ្លួនឲ្យនួនល្អង ៗ
តែងប្រកួកអួតធោមប្រលោមប្រុស
ត្រកូលខ្ពស់យល់ហើយមិនកន្ទង
នេះមកត្រូវកំដៅកក់ផង់ផង
នឹងស្នាណស្នងចងចិត្តស្នួទម្ដេចបាន ៗ
គន់ៗ គិតអាណិតនារីតូច
កើតក្នុងពូជហីនយសខុសសន្តាន
គោងត្រដររឿយយ៉ាកលំបាកប្រាណ
ទម្រាំបានមាសប្រាក់ធ្លាក់ដល់ចាស់ ៗ
ចាស់ហើយតើនឹងតែងតួម្ដេចល្អ
ប្រុសនឹងតថ្លៃទិញយល់ក្រណាស់
ឃើញជាចុះថ្លៃថោកល្មមបោកប្រាស

ការសង្វាសទឹងសង្វាតជាប់សន្វែង ។
សំណាងទន់ក្រជនតោងជន់អត់
ក្តីនឿយហត់រកស៊ីតាមដំណែង
គេអ្នកមានគេតែងកាយចិញ្ចែង
មិនដូចខ្លួននួនឯងកក់ស្រមក ។

អង្គុយគន់នារីឲ្យគិតសរង់
កប៉ាល់លឿនដល់ចុងអន្ទង់សក
ស្ទឹងកំពូបបត់កំខ្វីបប្អូនប្រេក
សំណាត់កកដេរដាសពាសពេញស្ទឹង ។
នាយតៃកុងកាច់ច័ក្រពុះសំណាត់
ច័ក្រក៏កាត់វ៉ាតណែនកប៉ាល់នឹង
ពួកម៉ាតឡូបាក់ថ្នោលដោលទទឹង
ច័ក្រក៏រេងផាត់វិលកប៉ាល់ព ។
ពួកអ្នកថ្នោលរឹងដោលសំណាត់ញែក
កប៉ាល់ជ្រែកវែកប្រានបានមួយគ្រា
សំណាត់ចុកកប៉ាល់ជាប់ច័ក្រខំពា
មើលវេទនាច័ក្រវើសំណាត់រឹត ។



ខ្ញុំគន់មើលសំណាត់វ៉ាត់កប៉ាល់
ដូចរាគកាល់រូបកាយចុះចរិត
តុំឲ្យរូបរើរួចពីទីល្វិត(១)
បំបាំងបិទត្រៃលក្ខណ៍បាត់ស្តី ។
កាមរាគរោលរឹតសត្វក្នុងលោក
ឲ្យសត្វនៅសៅសោកក្នុងលោកិយ៍
រាងកប៉ាល់ដូចរូបយើងប្រុសស្រី
ប្រាជ្ញាខ្វីមិនយល់គលត្រៃលក្ខណ៍ ។
ស្វាបច័ក្រគឺបញ្ញាន្ការកប្បកាត់
កងសំណាត់គឺរាគឲ្យលាកផ្ងាក់
បានរួចចេញចាកទុក្ខសោករោគរាក់
អាស្រ័យច័ក្រគឺបញ្ញាក្លៀវក្លាហាន ។
គ្រឿងកប៉ាល់ដូចកលអាការយើង
ដីទឹកភ្លើងខ្យល់គឺធាតុបួនស្ថាន
បង្កិតគឺសតិរំពុកបាន
ថ្នោលដោលប្រានគឺសមាធិចិត្តជាក់ ។

---

១ — តាមត្រូវ គឺ គងគត តែទីនេះ តម្រូវតាមពាក្យផ្ទួន ។

សំណាត់គឺបាបធម៌និវរណៈ

បិទបាំងគៈមិនឲ្យយល់ត្រៃលក្ខណ៍

ទឹកហូរវេល់ដូចកល់សង្សារចក្រ

ឲ្យសត្វធ្លាក់នៅក្នុងអន្លង់កាម ៗ

នូអវិជ្ជារូបកាយមិនណាយលាត

អំពីពាគនៅតែវង់ក្រឡង់តាម

បានជាដល់ទុក្ខមកយំរហាម

ព្រោះមិនតាមពុទ្ធកិច្ចភ្លេចស្មារតី ៗ

ខ្ញុំគិត ៗ គួរសេរង្វេគរូបអាត្មា

មកលុះពុះតណ្ហាការលោកិយ៍

ឃើញធម៌ហើយក៏នៅតែនឹកស្រើ

ជាចំណីពាគតែបិទមុខមាត់ ៗ

កាច់មិនបានប្រាទមិនបែរងតែបិទ

អនាថចិត្តអាណិតចៅមកប្រាសព្រាត់

គ្រាន់នឹងតាមព្រះបន្ទូលជាបខ្ជាត់

លោកិយ៍អត់កត់មិននឹងទទឹងគាង ៗ

យកធម៌ព្រះមកលះភ្លើងមិនឈប់ (



ងងឹតឈឹងដូចយប់មិនយល់រាង

នូលោកិយ៍លះក្រគ្រាន់តែព្រាង

ដូចគេលាងព្រៃខ្មៅត្រូវដងទឹក ៗ

ខំដុសលាងយ៉ាងណាមិនឡើងពណ៌

ជាតិជាដរជាប់នៅខ្មៅស្រមឹក

ដូចកិលេសជាច់សត្វចាត់ជាសឹក

អ្នកកុំទឹកគិតលាងឲ្យជ្រះបាន ៗ

ដូចរូបខ្ញុំខំលះរតតែរង

ទប់មិននឹងតាំងមិននៅផ្លូវកម្មដ្ឋាន

អង្គុយគិតយកធម៌ទូន្មានប្រាណ

ដូចគេប្រានសំណាត់សាត់មួយគ្រា ៗ

ដល់ហួសទៅសំណាត់សាត់មកវិញ

ប្រមូលពេញដូចដើមណាទួនណា

នូសំណាត់នេះប្រៀបដូចតួតណ្ហា

នឹងកាប់ឆ្ការយ៉ាងណាក៏ណែនវិញ ៗ

គន់សំណាត់សាត់ជាប់ក្នុងចំការ

ចាំងខ្មោចក្ដែខ្មោចឆ្នាត្រាពាសពេញ

ខ្លះរលួយខ្លះប្រេះពោះវៀនចេញ
ក្អែកត្មាតដេញគ្នាស៊ីជាភក្សា ៗ
ខ្ញុំគន់មើលសាកសពចំណីក្អែក
គិតសង្វេគដល់រូបនៃអាត្មា
ទុសត្វក្អែកមកលុះក្ដីមរណា
សូន្យដីរ៉ាគេបោលបណ្ដែតទឹក ៗ
កាលពីរស់កឹងកាចអំណាចមាន
សត្វតិរច្ឆានដូចគ្នាមិនហ៊ានចឹក
ដល់ខ្លួនស្លាប់គេអូសបណ្ដែតទឹក
ក្អែកត្មាតត្រឹកចឹកស៊ីមិនគ្រាន់ឡើយ ៗ
ទុអនិច្ចាសង្ខារសត្វទាំងឡាយ
តែបែកកាយរំលាយខ្លួនទៅហើយ
គេក៏កើតខ្ពើមឆ្អើមពុំជិតឡើយ
យើងគេអើយគួរគិតផ្លូវអនិច្ចា ៗ

ខ្ញុំបាទទំសង្វេគសាកអសុភ
ពគមិនឈប់ចេះតែពេលទាំងរូបា
នឹកតែទៅដល់ពៅកែវសុតា



អនិច្ចាថាតែមាត់ចិត្តមិនចំ ៗ
អសុភដប់សម្រាប់លោកលាងលោក
កំចាត់រាគចរិតចិត្តបឋម
ព្រះយោគីលោកសមាធិចុះអារម្មណ៍
បែកតែខ្ញុំពុំចំអារម្មណ៍ឡើយ ៗ
យកសពក្ដែមកប្រែទីងរូបកាយ
មិនរសាយណាយសោះណាលោកអើយ
ធ្វើម្ដេចហ្ន៎បានលោកឯណាអើយ
ជាកោះត្រើយណែផ្លូវឲ្យបានពា៎ ៗ
មួយសង្ស័យនឹងពាក្យ “អនុស្រសក”
ពាក្យប្រែបកដូច្នេះគួរសង្កា
សត្វអនុស្រ រាសកពីកាលណា
បានជាមកសញ្ញាឈ្មោះយ៉ាងនេះ ៗ
សត្វអនុស្រមិនដែលសកសោះទេ
នេះហេតុអ្វីក៏គេហៅដូច្នេះ
ឬគេឃើញសំណាកនៅនេះអេះ
បានជារិះត្រិះនាមមកឲ្យរ ៗ

រីឯពិនិត្យមិនយល់សែនធ្ងល់ពេក
ការឈ្មោះប្លែកនាមសត្វតាត់មិនត្រូវ
អន្ស្រែសក លោកណាឲ្យនាមហៅ
បានជានៅនាមជាប់ឥឡូវនេះ ។
តែបើគិតគួរកោតលោកបុរាណ
ចេះគិតអាចសន្មតនាមយ៉ាងនេះ
ទីព្រៃសោះចេះឲ្យឈ្មោះប្លោះប្លេះ
ពេញជាចេះកំណត់កត់នាមនៅ ។
អង្គុយគិតចិត្តភ្លើនរំភើយខ្យល់
កប៉ាល់គ្រឿនលឿនដល់ ព្រែកក្រពៅ
ទឹកក៏នឹងពុំហូរចុះទៀតទៅ
ឃើញទឹកខ្មៅថ្លាយង់ឥតពាគា ។
ក៏ដឹងថាជាទឹកទន្លេដល់
ទឹកស្ទឹងកល់ហូរទល់ប្រសព្វគ្នា
បានជានឹងពុំហូរត្រឹមនោះណា
នឹកសង្កា ព្រែកក្រពៅ ហៅសែនធ្ងល់ ។
ព្រែកនេះតើបែកមកពីណាអេះ



ឃើញតែចុងត្រឹមនេះមិនឃើញគល់
ឬព្រែកនេះទីនាបជាភាពទាល់
គួរពិភាល់ចិត្តណាស់ព្រែកក្នុងព្រៃ ។
ព្រែកនេះតើគេជីកឬកើតឯង
លោកមកតែងនាមក្រពៅនៅប្លេះនៃ
ខ្ញុំពិគ្រោះមិនអស់ក្តីសង្ស័យ
កប៉ាល់លឿនដល់កន្ទ្រែ ថ្ងៃក៏ទាប ។
ព្រែកកន្ទ្រែកាត់ត្រង់ត្រូវកញ្ឈោះ
ទីស្រឡះគេដើរបានរៀងរាប
ព្រៃដុះល្បោះ(១) ចុះតាមទីទំនាប
អ្នកស្វែងលាភរកត្រីអាស្រ័យបាន ។
ព្រែកកញ្ឈោះទីស្រឡះគេដើរដល់
ស្រុកមង្គលបូរីជាជ័យឋាន
គិតទៅ ៗ គួរកោតលោកបុរាណ
ចេះគិតអាចចាត់ព្រែកឈ្មោះប្លែកគ្នា ។
មួយសង្ស័យនឹងនាមកន្ទ្រែនេះ

១– តាមត្រូវ គឺ រពោះ ។

នរណារិះចាត់ឈ្មោះទុកច្នេះណា
វិស័យទីជាស្ថានព្រៃព្រឹក្សា
មកសញ្ញាហៅកន្ត្រៃសង្ស័យស៊ិន ៗ
ឬកន្ត្រៃលោកណាធ្លាក់នៅនេះ
បានជារិះយកនាមនេះមកគុណ
ឬមានជាងកន្ត្រៃគេនៅមុន
ឬអ្នកបុណ្យឲ្យឈ្មោះព្រោះជាប់គ្នា ៗ
រំពឹងគិតមិនយល់ដល់ព្រលប់
ពេលក៏យប់ម៉ោងមួយដល់បាក់ព្រា
តែកុងតាញសប្ដូឡើងបីសា
ប្រាប់នាវឲ្យបៀសកប៉ាល់ចូល ៗ
លុះចូលដល់ស្ពានផែមុខសាលា
បោះយុថ្កាចតចងតាមទំនួល
លោកមោនសៀ(១)នាយគយចិត្តស្រោះស្រួល
មកទទួលលោកធំ(២) ទៅគ្រឹហា ៗ

១— មកពីភាសាបារាំង Monsieur ។

២ – លោកធំ ជាពាក្យជំនាន់នោះ ហៅចំពោះ Résident បារាំង ដែលនៅត្រួតការប្រចាំទីរួមខេត្តនីមួយៗ ។



ចៅក្នាក់ង៉ារនាំឧសផ្ទុកកប៉ាល់
ដាក់ពេញតាល់ធាំងល្វែងនៃនាវ
លោកបាល័ដ្ឋចាត់លៀងមួយវេលា
ធាំងអស់គ្នាគេសែនសប្បាយចិត្ត ៗ
តែខ្ញុំមួយព្រួយព្រាណរំខានសល់
ចង់តែដល់បានយល់ចមបពិត្រ
អស់រាជការនឹងបានវិលស្ថានស្ថិត
មិនដឹងគិតកែផ្លូវឲ្យត្រូវឡើយ
អង្គុយគិតដើរគិតដូចពុលផ្សិត
ពគក៏តែពេលពលពមិនស្បើយ
លុះដល់ម៉ោងពីរខ្យល់រំភើយ
គ្រាន់លំហើយក្ដីទុក្ខពីមុខបាន ៗ
មើលទៅស្ទឹងបាក់ព្រាជាធ្លាធំ
ពួកអ្នកឈ្នួញមកជុំធាំងបីដាន
មួយគឺស្ទឹងមង្គលបូរីបាន
ពីរគឺជានព្រះដំបង បីទន្លេ ៗ

Phnom-Penh University LIBRARY
655

ទីស្ទឹងនោះកាលពដសៀមចាយថែក
ចាត់ឲ្យហៅសាមយ៉ែកភាសាគេ
ព្រោះដានបីចេញទៅមាត់ទន្លេ
បើតាមគេឃើញត្រូវជាផ្លូវបី ៗ
ឯពាក្យហៅបាក់ព្រាពីបុរាណ
គ្មានភិយ៉ាន(១)ឡាក់ហានទឹងរូបអ្វី
ឬបាក់ព្រា បាក់នេះជាពាក្យថ្មី
បុរាណស្តីថា បាត់កាំបិតព្រា? ៗ
នរណាបាត់កាំបិតនៅនេះអេះ
បានជាដាប់នាមនេះដូច្នេះណា
ស័ព្ទកាំបិតយល់លើសយារវាចា
មកសញ្ញាថាតែបាក់ព្រាវិញ ៗ
ទបានលោកប្រាជ្ញណាទឹងសួរសាក
ឲ្យដឹងពាក្យបាក់ព្រានេះឯងមិញ
រំពឹងទៅមិនយល់សល់សែនម្ចិញ

១– ភិយ៉ាន (សៀម) = គិតតាង ។



កាលណាលោកទឹងចេញកប៉ាល់ទៅ ៗ
រំខានទុក្ខទឹងមូសវ៉ាយ៉ាយី
ឯណាទុក្ខទឹងស៊ីម៉ៃម៉ីទៅ(១)
ឯណាទុក្ខទឹងទឹកដល់ធោមឆ្មៅ
ឯណាទុក្ខទឹងក្តៅចង្អៀតគ្នា ៗ
ទឹកទន្ទឹងបានតិចលេចឡុងបុក
លាបសសុទ្ធអុំអែបមកម្ម៉ា
លោកកុម្មីសែរកំឡើងកាន់នាវ
រុំឲ្យស្រាវយុក្កាចេញវៃ ៗ ៗ
ខ្ញុំគ្រាន់ស្បើយក្តីមោះព្រោះចង់ឆាប់
ច័ក្ររំង៏កាប់ទឹកខ្វាតខ្វូរពាំងព្រៃ
កប៉ាល់គ្រៀនលឿនលើជលាល័យ
បើគអស់ដៃមើលព្រៃប្រប៉ះគ្នា ៗ
ដល់ត្រែកពកាច់ប្រែបែរឧត្តរ
កំរែងចរតាមប៉ឋទីគង្គា
ទឹកសង្ស័យត្រែកពនេះមហិមា

១– ម៉ៃមីទៅ (ពាក្យសៀម) = ញាំបាយ ។

តាំងនាមាឃើញកើនលើសប្រមាណ ។
ពាក្យត្រៃភពប្រារព្ធនាមព្រះពុទ្ធ
មិនគួរគេមកចុតឈ្មោះភូមិឋាន
ទីនេះសោតពួកនេសាទគេរាប់អាន
តាំងជាស្ថានបាយាប(១)ចាប់ត្រីទេ ។
នេះហេតុអីយកនាមព្រះឲ្យឈ្មោះ
មិនគួរសោះនឹងពាក្យអ្នកទទេ
នរណាអេះបាត់នាមនេះមុនគេ
ឬគេភ្នេរព្រោះព្រៃកបែកបីគ្រោះ ។
សត្វត្រៃភពប្រែជាភពទាំងបី
ព្រះជិនស្រីជាត្រៃភពចំពោះ
ព្រោះព្រះអង្គវិសេសគុណពីរោះ
បានជាឈ្មោះព្រះចមត្រៃភពការ ។
ឯព្រៃកនេះពុំឃើញវិសេសអ្វី
វិសេសតែនឹងត្រីជាអាហារ
ពុំគួរតាំងនាមស្មើសាស្ត្រាចារ្យ
ឬហៅដោយរៅហារអស្ចារ្យត្រៃ ។

១— បាយាប = អារក្សទឹកសម្រាប់អ្នកនេសាទគោរព ។



រំពឹងគិតមិនយល់សត្វត្រៃភព
បង់តែឈប់ទៅមើលទីនោះនៃ
ជាមានអ្វីសាក្សីកណ្ដាលព្រៃ
គួរសង្ស័យនឹងពាក្យត្រៃភពនេះ ។
ឬសត្វត្រៃហៅត្រៃលោកតាំងឈ្មោះ
គង់ពីគ្រោះតាមហេតុមានប្លោះប្លុះ
ឬពីដើមព្រះយាងមកនៅនេះ
បានជារិះតាំងហៅត្រៃភពហោង ។
ឱលោកណាដឹងការហេតុដើមដាន
សូមមេត្តាប្រោសប្រាណប្រាប់ខ្ញុំផង
ខ្ញុំពីគ្រោះមិនយល់រឹងហ្មូហ្មង
កប៉ាល់ធ្ងន់កាត់យោគយាងយ៉ាវខ្ចុ ។
លឿនលន្ទឹមតាមបត់យានយ៉ាវត្រង់
កាត់តម្រង់បែរត្រង់ដល់ភូមិថ្មី
ភូមិនោះមានគេនៅជាប្រក្រតី
បត់ក៏ខ្ចីជាប់នាមពាបសីមា ។

ឱស្រុកពាមបាត់នាមឈ្មោះពិរោះ
គេបញ្ចុះសីមាពីកាលណា
ក្រោយខាងដើមមានព្រែកបែកជាស្នា
ឮគេថាស្ទឹងនោះទៅទឹកដោរ ៗ
ឱទឹកដោរទឹកហូរពីក្ដំណា
ធ្លាក់មកពាមសីមាផាសពេញពោរ
ទឹកទន្លេឡើងកល់ទល់មិនហូរ
កាត់ទឹកដោរដល់ព្រោតវត្តឈើខ្មៅ ៗ
គន់មើលទៅវត្តលោកលើគោកស្រួល
ជាទីទួលសមជាអាពមនៅ
ឯវត្តនេះយកនាមឈើមកហៅ
នាមឈើខ្មៅលោកណាតាំងនាមនេះ ៗ
ឬវត្តនេះស្រីខ្មៅចៅធ្វើទេ
យកនាមគេមកតាំងទុកដូច្នេះ
ឬពីដើមមានឈើខ្មៅនៅនេះ
បានជាវិះតាំងនាមមកឥឡូវ ៗ



ពាក្យឈើខ្មៅហៅហាក់នាមខ្មៅបង
ចិត្តចាប់ចងនឹកដល់កែវគោមឆ្ងៅ
ឱព្រះគុណព្រះកែវវត្តឈើខ្មៅ
ខ្ញុំណាទៅនគរវត្តព្រោតកនិដ្ឋា ៗ
សូមព្រះគុណប្រោសជួយចក្រពង្ស
ឲ្យស្តេចទ្រង់ចំរើនដោយយសា
ប្រោសប្រាណខ្ញុំឲ្យបានទីឧកញ៉ា
កប់សក្តារ៉ឪស៊ីសុវត្ថិ ៗ
មែនបើខ្ញុំសម្រេចដូចប្រាថ្នា
ខ្ញុំនឹងគិតហែផ្កាមកថ្វាយថ្វាត់
សូមកុសលព្រះគុណជួយបំបាត់
សព្វទុក្ខភេទខាត់សកលកាយ ៗ
មួយសូមជ័យជំនះឈ្នះសត្រូវ
ទៅតាមផ្លូវកុំឲ្យមានអន្តរាយ
ទាំងពាលម្រឹគយក្សយួនផងទាំងឡាយ
ចៀសឲ្យឆ្ងាយដោយអំណាចព្រះបមត្រៃ ៗ
ខ្ញុំសំពះបន់ព្រះវត្តឈើខ្មៅ

កប៉ាល់គ្រឿនលឿនទៅតាមជលស័យ
ត្រូវព្រះពាយរំភើយខ្ញុំនឿយក្រៃ
ក៏លក់តាមសម័យយប់នោះឯង ៗ
លុះបើកដល់មាត់ពីរបេញទន្លេ
កប៉ាល់រេបើកពុះឆ្លងវាលវែង
វាយោយោកផាត់មករលកផ្សង
ខ្ញុំបាទឯងក៏ក្រោកចាកដំណេក ៗ
អង្គុយគន់មើលទឹកទន្លេសាប
ឡើងលិចផាបព្រៃព្រឹក្សពន្លឹកពេក
មើលទៅទិសទក្សិណសែនវែង
ឃើញតែមេឃម្លូដិតឯទីតឈឹង ៗ
គន់ទៅទិសឧត្តរតល្បៀសាន
ឃើញជាដានព្រៃវង់វែងវឹង
មើលទៅទិសបស្ចិមវាលដូចបឹង
ទឹកឡើងនឹងពោរពេញមើលល្ហោះ ៗ ៗ
កប៉ាល់រឹងច័ក្រដើរស្ទើមិនឈប់
រលកខ្ទប់ស្ទើរខ្ទាត់ច័ក្រពានពុះ



រលកយោលខ្លោលឡើងដូចគេប៉ោះ
កប៉ាល់ស្ទុះទឹកបែកញែកសាចជះ ៗ
វាយោបោកកប៉ាល់បែរលេលឿន
រលកគ្រឿនច័ក្រគ្រាន់បើកជំនះ
តែកុងកាច់តាមកៀនរលកជះ
កប៉ាល់រះទឹកពយបែកថ្កាត្រែង ៗ
មើលទៅទឹកធំពន្លឹកគ្លូវតែខ្វាប
រលាមស្វាបលិចព្រៃមើលបែកផ្សង
នឹកសង្ស័យទន្លេសាបនេះឯង
លោកណាតែងនាមត្រូវទំនងម៉េះ ៗ
ពាក្យហៅថាទន្លេគ្នេរមិនដល់
សព្វនេះយល់មិនត្រូវពាក្យអ្នកបេះ
បាលីទឹកគ្មានតួ "ទ" ទេអេះ
ហៅជលេដូច្នេះទើបបានត្រូវ ៗ
នេះមកហៅទន្លេអក្សរ "ទ"
យក "ទ" ជា "ជ" ប្ដូរម្ដេចក្ដូវ

នេះទឹកដីនឹងសព្វសត្វមនុស្សម្នា
ឃើញពីរុធខុសគ្នាទៅតាំងផែន
ឯណាល្អក៏ល្អលើសតាំងដែន
ឯណាសោសោសែន(១)តាំងភាព ៗ
ដូចដីយើងបាត់ដំបងជាតិដីខ្មៅ
ធ្វើស្រែស្រូវកើតផលតែកល់គ្នា
ស្រុកសៀមរាបម្តេចដីខ្សាច់មហិមា
ធ្វើចំការស្រែស្រូវមិនសូវផល ៗ
មួយគឺខាងអឺរុបម្តេចចាត់ល្អ
មនុស្សក៏ចម្រើនធំតាំងសាកល
ខាងឥណ្ឌាមនុស្សខ្មៅៗពិកល
ខាងមណ្ឌលយើងម្តេចមនុស្សតូចទាប ៗ
មួយព្រឹក្សាលតានាមដូចគ្នា
សេទជាម្តេចខុសគ្នារៀងរាប

១— សោ ភាសាអ្នកស្រុកបាត់ដំបង-សៀមរាប បានន័យថា : អាក្រក់, គៀយហត់, តំរក់ ។ សោសែន = អាក្រក់ពេក ។



តាំងសត្វសោតក៏ខុសអត្តភាព
ខ្លះក៏ទាបខ្លះក៏ខ្ពស់ឃើញខុសគ្នា ៗ
បើអាឡា សាងមែនម្តេចដូច្នោះ
ខ្ញុំពីព្រោះមិនសមនឹងថ្វា ថា
វិស័យព្រះនោះប្រៀបដូចបិតា
គោងមេត្តាដល់បុត្រស្មើព្រះទ័យ ៗ
នេះមកសាងឲ្យកូនមិនស្មើមុខ
ជាអាពុកមនុស្សឬខុសនិស្ស័យ
ស្តាប់ទៅយល់មិនត្រូវអធ្យាស្រ័យ
ទឹកដីព្រៃក៏កើតដោយធម្មតា ៗ
ដូចយ៉ាងទឹកទន្លេនិងសមុទ្រ
ឃើញធំផុតទូលាយឆ្ងាយណាសា
ពួកអ្នកឈ្មួញដើរជួយរកគោក្តា
សឹងសែនមហាលំបាកដោយព្យុះខ្យល់ ៗ
ឬអាឡាឥច្ឆាពួកអ្នកឈ្មួញ
មិនឲ្យគ្នាដើរជួញក្រោមណ្ឌល
បានជាមកបង្កើតជាព្យុះខ្យល់

ឲ្យលិចលង់ទូកទ័លពាល់វេទនា ។
អើបើយ៉ាងខ្មែរយើងមិនចូលសាសន៍
គួរធ្វើផ្លាស់ទៅចុះក៏ឥតថា
ចុះពួកផ្កាដែលគ្នាខំឧស្សាហ៍
ប្រតិបត្តិសព្វគ្រាតាមមហាម៉ាត់ ។
ឯណាយប់គ្នាបួសកាន់ខន្តី
ថ្ងៃឡើងធ្មៀតបង់ត្រីសំឡេះសត្វ
ឯណាគ្នាហ៊ានឲ្យតុកតួនកាត់
ខំប្រតិបត្តិមហាម៉ាត់មិនឲ្យគ្គង ។
គួរឬអាល័សៈឡើមិនប្រោសប្រាណ
មកក្លែងធ្វើផលបានធំកន្ទង
គ្នានាំព្រៃទៅលក់ស្រុកបាត់ដំបង
ឲ្យគ្នាហ្មងធ្ងង់ទៅត្រូវព្យុះខ្យល់ ។
បើយើងជាអាល័សៈឡើមិនធ្វើច្នេះ
ទីត្រង់ណោះគួរធ្វើឲ្យកើតថ្នល់
ឲ្យអ្នកទូកដើរស្រួលមិនគោងវល់



នឹងព្យុះខ្យល់ដូចយ៉ាងអាឡ្លាសាង ។
ទីត្រង់នោះគួរសាងជាកោះធំ
ឲ្យកិរិយមនុស្សនៅតាំងសង់ខាង
តាំងក្បាលកោះឲ្យកើតជាព្រះប្រាង្គណា
មានមាត់បាងចូលចេញឲ្យសប្បាយ ។
នេះអាឡ្លាមកសាងទន្លេសាប
ជាលតែទឹកទៅពបទូលាយឆ្ងាយ
មនុស្សទៅមកសែនយ៉ាកលំបាកកាយ
ព្រោះអន្តរាយដោយខ្យល់តែពល់គ្នា ។
អើពួកផ្កាគេថាព្រះគេសាង
នឹងអែបអាងមិនសមនឹងកិរិយា
ពាក្យនេះអញ្ជើញពិចារណា
ជាយកខាងធម្មតាឬអស់លោក ។
ឬយកខាងព្រះអាឡ្លាដែលថានោះ
សូមពិគ្រោះមើលចុះតាមអធ្យាក
ឯទឹកដីថ្ងៃខែសម្រាប់លោក

655

គួរប្រយោគមើលហេតុមើលកិរិយា ។
កប៉ាល់ដើរលុះដល់ចុងក្បៀសថ្កាត់
តៃកុងបាត់ចូលបតបោះយុថ្កា
នាំគ្នាដេកសម្រាន្តតាមធម្មតា
អនិច្ចាតែខ្ញុំពុំលក់ឡើយ ។
ពុលរលកក្អករលឹកនឹកដល់ផ្ទះ
កត់មិនឈ្នះគះមិនទីងព្រលឹងអើយ
ត្រូវមកដេកកប៉ាល់ខ្យល់ក្ហើយ ៗ
ផាត់រំកើយរលកបោកឆា ៗ ។
គន់ទៅខាងឃើញសើន(១)គោមពីរក្បោះ
ភ្លើងភ្លឺប្រុះប្រុង ៗ ក្នុងគង្គា
គោមពីរនោះឆេះនៅសព្វវេលា
តាំងជាធ្លាប្រាប់ផ្លូវស្រុកសៀមរាប ។
ខាងមាត់ពីរកើតតាំងគោមឆ្វេងស្តាំ
អុជប្រចាំចូលចេញទន្លេសាប

១— ជើងគោម ឬប៉មខ្ពស់ សម្រាប់យាមល្បាត ។



ខ្ញុំគន់ ៗ នឹកកោតលោកដពប
មកលះបាបលោកបុណ្យចេញធនធាន ។
ទិញប្រេងអុជគ្រប់ឋានតាមទន្លេ
ទុកឲ្យគេអ្នកដើរក្នុងជលឋាន
ដល់ពេលយប់នឹងដឹងទីដែនដាន
ចេញចូលបានឥតមានក្តីចែងវែង ។
គោមនោះសោតឆេះនៅជាប្រក្រតី
ដល់រាត្រីទើបឃើញភ្លើងភ្លឺទេង
ដល់ពេលថ្ងៃពុំយល់ព្រោះសូរ្យសែង
គេបាត់ចែងថែមប្រេងដប់ថ្ងៃម្តង ។
ខ្ញុំយល់ ៗ សរសើរលោកបារាំង
លោកមកតាំងអុជគោមភ្លឺកន្លង
ប្រាថ្នាទុកជាទានឲ្យអ្នកផង
បានដើរឆ្ពង់ឃើញភ្លើងជាសញ្ញា ។
ឱស្រុកខ្មែរតាំងតែពីនេះទៅ
មានតែសុខឥតសៅឥតទុក្ខា

បានបាំងលោកតាំងគ្រងរក្សា
តែងសីមាកម្ពុជាឲ្យពណ្ណរាយ ៗ
តែត្រឹមទីទន្លេជាស្ថានស្ងាត់
មកបេះបាត់អុជភ្លើងប្រចាំហ្វាយ
ពស្ត្រទៅមករកតាមស្រុកឆ្ងាយ ៗ
ដើរសប្បាយមិនគោងវង្វេងផ្លូវ ៗ
ទទន្លេតាំងតែពីបុរាណ
មិនដែលមាននរណាបំភ្លៅ
ឥឡូវនេះមកបានបាំងនៅ
ឲ្យអុជគោមទូទៅតាំងគង្គា ៗ
សែនរុងរឿងថ្កើងហើយទន្លេសាប
ពីនេះទៅជបឥតភ័យា
ទត្រើយប់នេះជូនវេលា
ខ្ញុំនិទ្រាពុំលក់ជាទុក្ខក្រៃ ៗ
បែរទៅទិលចូតិឃើញស្ទឹ
ព្រះនៀអរុណរះសែងថ្ងៃ



ពួកកប៉ាល់ក៏ភ្ញាក់ឡើងទីទៃ
ស្រាវយុត្តាវៃៗ ថយម៉ឺម៉ា ៗ
កប៉ាល់គ្រឿនលឿនចូលទៅតាមព្រែក
ណាចង្អៀតក៏ជ្រែកបែកជាគ្នា
តែកុងកាច់បត់តាមទីគង្គា
មើលព្រឹក្សាដុះហែតាមក្បែរផ្លូវ ៗ
ខ្លះដើមខ្ពស់លូតលាស់ខ្នែងលំពង់
ខ្លះទាបទឹកលិចចុងឃើញខ្មៅ ៗ
គោតហ៊្នុំឈើនាមធន់ណាស់ទៅ
ទឹកលិចនៅប្រាំខែប្រែមិនក្បេយ ៗ
ទព្រៃអើយព្រៃដុះជារនាម
ខ្លះជាពមស្បាតជិតបិទសែងថ្ងៃ
ខ្លះខ្ពស់ស្រោងផុតទឹកពន្ទឹកក្រៃ
សត្វអាស្រ័យជាស្ថានសម្រាន្តនៅ ៗ
កប៉ាល់បើកលុះដល់កន្ទាយគង
ឃើញភ្នំក្រោមនៅខាងឯលិចផ្លូវ
ទភ្នំក្រោមតូចល្អមមានមនុស្សនៅ

មើល ៗ ទៅពុំឃើញមានដើមឈើ ៗ
ជាភ្នំដិលត្រងិលមានតែស្មៅ
មានដើមពោធិមួយនៅកំពូលលើ
ក្រោយពោធិមានវិហារគេទើបធ្វើ
វត្តនោះតើលោកណាសង្ឃសាង ៗ
ឯក្រោយធ្លាវិហារមានប្រាសាទ
វិចិត្រស្អាតដោយថ្មកជាប្រាង្គ
ជារបស់បុរាណលោកសំអាង
ទំនងយ៉ាងបញ្ចុះព្រះធាតុក្សត្រ ៗ
ឬជាទីតម្កល់ព្រះបដិមា
សម្រាប់អ្នកសាសនាឡើងប្រណិបតន៍
ឲប្រាង្គនេះលោកណាមកថែងតាត់
មាននៅស្ពានបង្អាត់ខឿនខ្ជាត់ខ្វែង ៗ
ឥឡូវនេះជំរុតទ្រុឌទ្រោមធ្លាយ
ថ្មរុះពាយតាមជាយជើងកំពែង
ស្តាយអើយស្តាយប្រាសាទប្រសើរស្តែង
បានលោកណាតាត់ថែងជួសជាថ្មី ៗ



មើលប្រាសាទលើភ្នំស្ទើរយំស្តាយ
មិនគួរមកអន្តរាយខ្ចាយដោយដី
ស្តាយតែស្នាដៃធ្វើស្មើកោសី
មិនគួរបីបែកបាក់ធ្លាក់ធ្លាយផ្ទុះ ៗ
ខាងជើងភ្នំមានវត្តលោកសង្ឃនៅ
មានផ្លូវឡើងទៅខាងវត្តនោះ
ឲភ្នំនេះស្តាប់ទៅយល់ពិរោះ
សញ្ញាឈ្មោះភ្នំក្រោមល្មមមានអាង ៗ
ព្រោះភ្នំគេសង់តែនៅខាងលើ
មានដើមឈើដុះលើឃើញច្រូងច្រាង
ភ្នំមួយនេះមកតាំងនៅក្នុងបាង
មានទីអាងយ៉ាងនេះជាសាក្សី ៗ
បានជាហៅភ្នំក្រោមព្រោះក្រោមគេ
នៅខាងជាយទន្លេអ្នកធ្វើត្រី
ឥឡូវមានអ្នកស្រុកនៅប្រក្រតី
ដាំឫស្សីដូងស្វាចំការបេក ៗ
ឲភ្នំនេះជាទីតីបុរាណ

សមជាស្ថានសំណាក់អ្នកវិវេក

នឹកសរសើរប្រាសាទប្រសើរពេក

ខ្ញុំក្រឡេកមើលទៅទីឧត្តម ៗ

ឃើញទីនាំងតាំងបតនៅរៀងរាយ

ប្រចាំទ្វីបម្ភក្លាយកៈសាយណា

ទូកតែហៅវ៉ៃតម្បូងកាពផាយម៉ា(១)

ក៏ដឹងថាព្រះទីនាំងព្រះចក្រី ៗ

ចៅភ្នាក់ងារត្រួតត្រាព្រះទីនាំង

ឲ្យបតតាំងតាមថៃវបុនព្រែកថ្មី

ទូកពជរង្សបតក្នុងទូកកុងវ៉ៃយ

ក្រុមមន្ត្រីបតអមលោមក្រៅផ្លា ៗ

ទូកអស់នេះទ្រង់ឲ្យមកប្រចាំ

មុនខម្រាំព្រះបរមរាជា

ដល់ដប់កើតថ្ងៃសុក្រស្ដេចលីលា

យាងដោយរាជនាវាកប៉ាល់ធំ ៗ

១— ភាពលេះផាយ គឺទូកទីតាំងអ្ពះ ។



លុះកប៉ាល់រាជការស្រុកព្រះដំបង

ទៅដល់ដងរាលវែងជាចុងកុម(១)

លោកឲ្យបោះយុថ្កាបតប្រជុំ

អ្នកជំទុំនាំគ្នាមើលត្រៀបត្រា ៗ

លុះកប៉ាល់បតស្រេចលេចទូកបី

ក្រុមមន្ត្រីសៀមរាបទីឧកញ៉ា

មកទទួលលោកធំជាឥស្សរា

ថីគេបកកាសាថែងការផង ៗ

លោកកុម្មិសែរអធ្យាស្រ័យតាមហេតុ

ចាត់ឲ្យលោកទៅហ្វាយខែត្រព្រះដំបង

នៅកប៉ាល់ឯក្រោយចាំព៉ប់រង

ទទួលអគ្គច្បាស់ច្បងស្ដេចយាត្រា ៗ

តែខ្លួនលោកទឹងលោកសង្ឃបីអង្គ

ពុំរង់ចុះទូកអ្នកឧកញ៉ា

ខ្ញុំបាទឯងជាបាវលោកមេត្តា

ឲ្យយាត្រាទៅមុនដោយក៏សាន្ត ៗ

១ – តាមត្រូវគឺបុងភូមិ តែខេះតម្រូវតាមសម្ពស្សកាព្យ ។

ទើបជញ្ជូនហិបពូកដាក់ទូកស្រេច
មួយរំពេចក៏ចេញតាមជលស្ថាន
ពួកកំណែនគេណ្ដាចែវចំចែវប្រាន
កាត់ត្រង់ដានរីជ្រៃទឹកព្រែកដីកថ្មី ៗ
ចែវអែបរ៉ែបអបខាងព្រះទីនាំង
ខ្ញុំក៏តាំងលួចគន់មើលស្រីៗ
ពួកអ្នកក្នុងតែងអង្គល្អប្រិមប្រិយ៍
ធរីកក្រ្តហាក់ស្រីទេពកញ្ញា ៗ
សឹងប្រដាប់សង្វារចារ៉ុខ្សែដៃ
ទំហ៊ូផ្ទៃវិចិត្ររចនា
ទទឹមពេជ្រលេចសែងព្រះសុរិយា
សូរ្យកាន្តកែវកាញ្ចនាប៉ព្រាតព្រាយ ៗ
ស្លៀកខៀនខាត់តែអាវខាំម៉ាស៊ី(១)
ផាត់ធរីគន្ធរសពិដោរសាយ
ខ្លះតែងតួសុភាពភាពសៀមក្លាយ

១– ខាំម៉ាស៊ី = ក្រម៉ាស៊ី ជាក្រមាគពក់ ។



ខ្លះតែងកាយអាវសាយក្លាយបាំង ៗ
ពួកសាវឡឹកផ្លូតទឹកប្រឡែងគ្នា
សើចហេហាហែលខាងព្រះទីនាំង
ខ្លះមិនខ្លាចអំណាចពួកក្រុមវាំង
ក៏សើចខ្លាំងលើសគេរៀតែខ្លួន ៗ
ខ្លះអង្គុយសិតសក់ក្បាក់ខាង
ខ្លះសំអាងសមសក្តិហាក់ទំនួន
តែងប្រកួតអួតអង្គទ្រង់ដោយខ្លួន
មើលសមសួនសមសក្តិព្រះចក្រា ៗ
ខ្ញុំគន់ ៗ សរសើរព្រះបារមី
ព្រះចក្រីជាត្បូងលើកេសា
កបនារីស្អាតៗ បាទបរិចា(១)
សែនមហាចំរើនព្រះកិត្តិយស ៗ
គន់ទៅទូកពួកសេវកាមាត្យ
សឹងស្អាត ៗ រុងរឿងដោយគ្រឿងខ្ពស់
តែងប្រកួតអួតគ្នាតាមសក្តិយស

១– ក្លាយពី បាទបរិចារិកា = ស្ត្រីអ្នកបម្រើជិតជើង។